# ការសម្ភាសន៍របស់អ្នកមីង ញ៉ៅ វ៉ាន

កៈ អ្នកសំភាសន៍ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសំភាសន៍ ញ៉ៅ វ៉ាន

## ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ ញ៉ៅ វ៉ាន

សង្ខេបៈ អ្នកមីង ញ៉ៅ វ៉ាន គាត់មានអាយុសែសិបបីឆ្នាំ ហើយគាត់កើតនៅភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ហើយគាត់មានបងប្អូនចំនួន បីនាក់ហើយគាត់ជាបងគេនៅក្នុងក្រុមគ្រួសារ ហើយគាត់មានប្អូនប្រុសពីរនាក់ទៀត។ គាត់បានរៀបការនៅពេលគាត់មានអាយុដប់ប្រាំបួនឆ្នាំ ហើយគាត់មានកូនពីរនាក់ ប្រុសម្នាក់ ស្រីម្នាក់ ហើយសព្វថ្ងៃពួកគេបានរៀបការរួច ហើយ។ នៅជំនាន់ពលពតគេបានជំលៀសគាត់អោយទៅនៅតាំងក្រសាំង ខេត្តកំពង់ធំ នៅពេលនោះឪពុករបស់គាត់នៅផ្សេង ហើយគាត់នៅផ្សេង ហើយម្តាយរបស់គាត់នឹងប្អូនពីរនាក់ទៀតនៅផ្សេង។ កាលសម័យនោះគាត់មានអាយុដប់ពីរឆ្នាំ ចឹងគេបានចាត់តាំងអោយគាត់ទៅជញ្ជូនកណ្តាប់ ហើយគាត់បានប្រាប់ថា គេអត់អោយដេកទេ តែមានមនុស្សចាស់ខ្លះគេបានអោយគាត់ទៅដេកព្រោះគាត់មានអាយុក្មេងជាងគេ ហើយដល់ពេលពួកពលពតមកបានគេទៅដាស់គាត់អោយមក វិញ។ ជីវិតរបស់គាត់មានការលំបាកច្រើន តែគាត់នៅតែតស៊ូយ៉ាងខ្លាំង។ធ្វើឡើងនៅភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី២៩ ខែ០៦ ឆ្នាំ២០១៨៕

កៈ អញ្ចឹងជាដំបូង សុំជំរាបសួរអ្នកមីង ខ្ញុំឈ្មោះ គង់ ចាន់ណាក់ ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិ ផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជាដែលគម្រោងនឹងធ្វើឡើងដោយសាកលវិទ្យាល័យមួយនៅ សហរដ្ឋ អាមេរិចដែលមានឈ្មោះថា សាកលវិទ្យាល័យ ប៊ី វ៉ាយ យូ ដោយសារតែសាកលវិទ្យាល័យមាន គោលបំណងចង់ជួយថែរក្សាប្រវត្តិរបស់ប្រជាជនខ្មែរទុក ដើម្បីទុកអោយកូនចៅជំនាន់ក្រោយ ពួកគាត់អាចរៀនអំពីប្រវត្តិរបស់ជីដូនជីតាហើយនឹងឪពុកម្តាយ។ ហើយអញ្ចឹងសំរាប់ការសម្ភាសន៍ របស់យើងធ្វើនៅភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ហើយយើងធ្វើឡើងនៅ ថ្ងៃទី២៩ ខែ០៦ ឆ្នាំ២០១៨។ ហើយអញ្ចឹង

សំរាប់ការសម្ភាសន៍នឹងយើងនឹងថតជាសំលេង ហើយ
នឹងថតជារូបភាពដើម្បីយើងផ្ញើរទៅសាកលវិទ្យាល័យដើម្បីគាត់អាចដាក់នៅលើវេបសាយ
របស់ សាកលវិទ្យាល័យ។ ហើយអញ្ចឹង
តើអ្នកមីងយល់ព្រមអោយពួកយើងយកសំលេងហើយនឹង
រូបភាពរបស់អ្នកមីងដើម្បីដាក់នៅលើវេបសាយរបស់សាកលវិទ្យាបានទេ អ្នកមីង?

ខ៖ អោយ។

ក៖
អញ្ចឹងអរគុណច្រើនសំរាប់អ្នកមីងដែលបានអនុញ្ញាតិអោយខ្ញុំយកសំលេងហើយនឹងរូបថត
របស់ អ្នកមីងដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។
ហើយអញ្ចឹងដំបូងសុំសួរអ្នកមីង តើអ្នកមីង មានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ខ្ញុំឈ្មោះ ញ៉ៅ វ៉ាន។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានឈ្មោះហៅក្រៅទេ អ្នកមីង?

ខ៖ អត់មានទេ។

ក៖ អត់មានទេ! ហើយអញ្ចឹង តើកាលនៅក្មេងៗគេហៅឈ្មោះរបស់អ្នកមីងថាម៉េចដែរ
អ្នកមីង?

ខ៖ គេហៅតែឈ្មោះនឹងទេ។

ក៖ គេហៅតែឈ្មោះវ៉ាននឹងដដែល។ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ
តើអ្នកមីងមានអាយុប៉ុន្មាន ឆ្នាំហើយ អ្នកមីង?

ខ៖ សព្វថ្ងៃនេះខ្ញុំមានអាយុហាសិបបីឆ្នាំ។

ក៖ អ្នកមីងមានអាយុហាសិបបីឆ្នាំ! ហើយអញ្ចឹង តើអ្នកមីងមានចាំថា
អ្នកមីងបានកើតនៅឆ្នាំណាទេ?

ខ៖ អត់ចាំទេ។

ក៖ អ្នកមីងអត់ចាំទេ អញ្ចឹងអ្នកមីងអាយុហាសិបបីឆ្នាំ
ចឹងអ្នកមីងប្រហែលជាកើតឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំ។
ហើយអញ្ចឹងសំរាប់ឆ្នាំខ្មែរវិញ តើអ្នកមីងបានកើតឆ្នាំអ្វីដែរ អ្នកមីង?

ខ៖ ខ្ញុំកើតឆ្នាំមមី។

កៈ អ្នកមីងកើតឆ្នាំមមី! ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងបានកើតនៅក្នុងខេត្តណាដែរ អ្នកមីង?

ខៈ ខ្ញុំកើតនៅនឹង។

កៈ អូ! អ្នកមីងបានកើតនៅខេត្តត្បូងឃ្មុំយើងនឹង។

ខៈ ចាំ!

កៈ ហើយអញ្ចឹង តើអ្នកមីងបានកើតនៅភូមិ ឃុំ ស្រុក ឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។

កៈ ហើយអញ្ចឹងសំរាប់អ្នកមីង មានបងប្អូនចំនួនប៉ុន្មាននាក់ដែរ អ្នកមីង?

ខៈ ខ្ញុំមានបងប្អូនចំនួនបីនាក់។

កៈ ហើយអញ្ចឹង តើអ្នកមីងជាកូនទីប៉ុន្មាននៅក្នុងក្រុមគ្រួសារដែរ អ្នកមីង?

ខៈ ខ្ញុំជាកូនទីមួយ។

កៈ អូ! អ្នកមីងបងគេ! ហើយអញ្ចឹងសំរាប់បងប្អូនរបស់អ្នកមីងមានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់ដែរ អ្នកមីង?

ខៈ ស្រីម្នាក់ខ្ញុំនឹង ហើយនឹងប្អូនប្រុសពីរនាក់។

កៈ ហើយអញ្ចឹងតើអ្នកមីងអាចជួយរៀបរាប់ឈ្មោះបងប្អូនរបស់អ្នកមីងទាំងអស់បានទេ អ្នកមីង?

ខៈ បងប្អូនរបស់ខ្ញុំគាត់ឈ្មោះ រស់ ហើយនឹងឈ្មោះ គឿន។

កៈ ឈ្មោះរស់ ហើយនឹងឈ្មោះ គឿន ហើយនឹងអ្នកមីង។ ហើយអញ្ចឹង ពេលនៅក្មេងៗតើអ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនរបស់អ្នកមីង?

ខៈ មានធ្វើអីវាទេ មានតែចិញ្ចឹមវាថែមព្រោះអីម្ដាយស្លាប់ចោលតាំងតែអាយុដប់ពីរឆ្នាំ។

កៈ ហើយអញ្ចឹង តើមានធ្លាប់ទៅធ្វើស្រែចំការជាមួយគ្នាទេ អ្នកមីង?

ខៈ នៅតូចៗមើលតែក្របីនឹង។

ក៖ អូ! មើលក្របីជាមួយគ្នា! ហើយអញ្ចឹងសព្វថ្ងៃនេះបងប្អូនរបស់អ្នកមីង
តើពួកគាត់រស់នៅកន្លែងណាដែរ អ្នកមីង?

ខ៖ ម្នាក់ទៅស៊ីឈ្នួលគេនៅប្រទេសថៃ ហើយមួយទៀតនៅចំការ។

ក៖ ចំការ នៅណាដែរ អ្នកមីង?

ខ៖ អូ! ចំការនៅខេត្តស្ទឹងត្រែង។

ក៖ ហើយអញ្ចឹងសព្វថ្ងៃនេះបងប្អូនរបស់អ្នកមីង តើពួកគាត់ធ្វើការងារអ្វីដែរ អ្នកមីង?

ខ៖ ម្នាក់ទិញដីចំការ។

ក៖ ហើយអញ្ចឹង តើចំការនឹងដាំអីគេដែរ អ្នកមីង?

ខ៖ ដាំស្វាយចន្ទី។

ក៖ ហើយអញ្ចឹងសំរាប់បងប្អូនប្រុសម្នាក់ដែលរស់នៅប្រទេសថៃនឹង
តើគាត់ធ្វើការងារអ្វីដែរ អ្នកមីង?

ខ៖ ធ្វើការងាររោងចក្រ តែមិនដឹងថារោងចក្រអីទេ ដែកមិនដឹង អីមិនដឹងទេ។

ក៖ ហើយអញ្ចឹងសំរាប់ម្តាយរបស់អ្នកមីង តើគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់ឈ្មោះ ស៊ូ។

ក៖ ហើយអញ្ចឹងសំរាប់ម្តាយរបស់អ្នកមីង តើគាត់មានស្រុកកំណើតនៅកន្លែងណាដែរ
អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់មានស្រុកកំណើតនៅភូមិនឹងដែរ។

ក៖ ហើយអញ្ចឹង តើម្តាយរបស់អ្នកមីងគាត់កើតនៅពេលណា អ្នកមីងមានចាំទេ?

ខ៖ អត់ចាំទេ មិនគាត់កើតពេលណាទេ ដឹងតែគាត់កើតឆ្នាំរកា។

ក៖ អូ! អញ្ចឹងគាត់កើតឆ្នាំខ្មែរឆ្នាំរកា។ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ
តើម្តាយរបស់អ្នកមីងគាត់នៅរស់ ឬមួយគាត់បានស្លាប់ហើយ អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់បានស្លាប់ហើយ។

កៈ ហើយអញ្ចឹង ពេលដែលម្ដាយរបស់អ្នកមីងបានស្លាប់ តើអ្នកមីងមានអាយុប៉ុន្មានឆ្នាះហើយ អ្នកមីង?

ខៈ ពេលម្ដាយរបស់ខ្ញុំគាត់ស្លាប់ ខ្ញុំមានអាយុដប់ពីរឆ្នាំ។

កៈ អូ! អ្នកមីងអាយុដប់ពីរឆ្នាំ នៅតូចៗណាស់ អញ្ចឹងគាត់ស្លាប់សាម សែសិបឆ្នាំហើយ។

ខៈ ហ្នឹងហើយ! ឥលូវរបស់ខ្ញុំគាត់អាយុសាម សែសិបឆ្នាំអស់ហើយ។

កៈ ហើយអញ្ចឹង កាលដែលម្ដាយរបស់អ្នកមីងគាត់នៅរស់ តើគាត់ធ្វើអ្វីដើម្បីចិញ្ចឹមជីវិតដែរ អ្នកមីង?

ខៈ ម្ដាយរបស់ខ្ញុំគាត់ធ្វើស្រែ។

កៈ អូ! ម្ដាយរបស់អ្នកមីងគាត់ធ្វើស្រែ។ ហើយអញ្ចឹង សំរាប់ម្ដាយរបស់អ្នកមីងគាត់មានចរិតបែបណាដែរ អ្នកមីង?

ខៈ ម្ដាយរបស់ខ្ញុំគាត់ស្រឡាញ់សឹងងាប់ហើយនឹង តែគ្រានតែគាត់អាយុខ្លី។

កៈ ហើយអញ្ចឹង សំរាប់ឪពុករបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់ឈ្មោះ ញ៉ៅ។

កៈ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ តើឪពុករបស់អ្នកមីងគាត់មានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់ស្លាប់ដែរហើយនឹង មិនដឹងគាត់អាយុប៉ុន្មានទេ តែគាត់កើតឆ្នាំមមែ។

កៈ អូ! គាត់កើតឆ្នាំខ្មែរឆ្នាំមមែ។ ហើយអញ្ចឹង តើឪពុករបស់អ្នកមីងនឹងគាត់បានកើតនៅកន្លែងណាដែរ អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់កើតនៅភូមិផ្ចត់ដំរី។

កៈ អូ! ឪពុករបស់អ្នកមីងគាត់កើតនៅភូមិផ្ចត់ដំរី។ ហើយអញ្ចឹង តើឪពុករបស់អ្នកមីងគាត់កើតនៅភូមិផ្ចត់ដំរីខាងណាដែរ អ្នកមីង?

ខៈ ឪពុកខ្ញុំគាត់កើតនៅភូមិផ្ចត់ដំរីខាងជើង។

កៈ ហើយអញ្ចឹង តើឪពុករបស់អ្នកមីងកើតក្នុងឆ្នាំខ្មែរ ឆ្នាំអ្វីដែរ អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់កើតឆ្នាំមមី។

កៈ ហើយអញ្ចឹង ពេលដែលឪពុករបស់អ្នកមីងគាត់បានស្លាប់នឹង
តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់ទើបតែស្លាប់ឆ្នាំទៅនឹង។

កៈ អូ! អញ្ចឹងឪពុករបស់អ្នកមីងគាត់ទើបតែស្លាប់ទេ គាត់ទើបតែស្លាប់បានជាងមួយឆ្នាំទេ។
ហើយ អញ្ចឹង ពេលដែលឪពុករបស់អ្នកមីងគាត់បានស្លាប់នឹង
តើគាត់មានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំពេលគាត់ស្លាប់គាត់មានអាយុចិតសិបឆ្នាំហើយ។

កៈ ហើយអញ្ចឹង ពេលដែលឪពុករបស់អ្នកមីងគាត់នៅរស់នឹង តើគាត់ធ្វើការងារអ្វីដែរ
អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់គ្មានធ្វើអ្វីទេ ធ្វើតែស្រែនឹងដូចតែគ្នានឹង ដឹកគោដឹកអីទៅ
គ្មានជំនួញជួនដូរអី នឹងគេទេ។

កៈ ហើយអញ្ចឹង តើអ្នកមីងធ្លាប់មានអនុស្សាវរីយ៍អ្វីល្អៗជាមួយឪពុកម្តាយរបស់អ្នកមីងទេ?

ខៈ មានទៅស្អី ល្អៗទៅមានអីអោយហូបក៏ហូបទៅ។

កៈ ហើយអញ្ចឹង ឧស្សាហ៍ទិញអីអោយគាត់ហូបដែរ មែនទេអ្នកមីង?

ខៈ ចាំ!

កៈ ហើយអញ្ចឹងសំរាបឪពុកម្តាយរបស់អ្នកមីង
តើពួកគាត់ធ្លាប់ប្រាប់អ្នកមីងអំពីជីវិតរបស់គាត់កាលពួកគាត់នៅក្មេងៗដល់អ្នកមីងទេ?

ខៈ ពួកគាត់អត់ដែលបានប្រាប់ទេ។

កៈ ហើយអញ្ចឹងសំរាប់អ្នកមីង
តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតាខាងម្តាយរបស់អ្នកមីងទេ?

ខៈ ជីដូនជីតាខាងម្តាយរបស់ខ្ញុំគាត់ឈ្មោះ យាយ សន តា ម៉ុត។

កៈ ឈ្មោះយាយសន តាម៉ុត! ហើយអញ្ចឹងសំរាប់ជីដូនជីតាខាងម្តាយរបស់អ្នកមីង
តើពួកគាត់បានកើតនៅកន្លែងណា អ្នកមីងមាននៅចាំទេ?

ខៈ ជីដូនជីតាខាងម្តាយរបស់ខ្ញុំពួកគាត់កើតនៅភូមិក្រពើសារ។

កៈ ហើយអញ្ចឹង តើជីដូនជីតាខាងម្ដាយរបស់អ្នកមីងពួកគាត់កើតនៅពេលណា អ្នកមីងចាំទេ?

ខៈ មិនចាំទេ តែម៉ែឪខ្លួនឯងមិនចាំផង ទំរាំជីដូនជីតាទៀត។

កៈ ហើយអញ្ចឹង ជីដូនជីតាខាងម្ដាយរបស់អ្នកមីងពួកគាត់បានស្លាប់យូរហើយ អ្នកមីង?

ខៈ ចាំ! ពួកគាត់ស្លាប់យូរហើយតាំងពីមកពីជំនាន់ពលពតវិញណោះ។

កៈ អូ! តាំងពីមកពីជំនាន់ពលពតពួកគាត់ស្លាប់តែម្ដង។ ហើយអញ្ចឹង តើពួកគាត់បានស្លាប់ដោយសារមូលហេតុអ្វីដែរ អ្នកមីង?

ខៈ ពួកគាត់ស្លាប់ដោយសារគាត់ឈឺ គាត់ចាស់ទៅ។

កៈ អូ! អញ្ចឹងគាត់ចាស់ជរាហើយ។ ហើយអញ្ចឹងពេលដែលជីដូនជីតាខាងម្ដាយរបស់អ្នកមីងគាត់បានស្លាប់ប្រហែលជាអាយុប៉ុន្មានឆ្នាំដែរ អ្នកមីង?

ខៈ មិនដឹងទេ ពួកគាត់ស្លាប់នឹងប្រហែលអាយុចិត ប៉ែតសិបឆ្នាំហើយ។

កៈ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងធ្លាប់មាន អនុស្សាវរីយ៍អ្វីល្អៗជាមួយជីដូនជីតាខាងម្ដាយរបស់អ្នកមីងទេ?

ខៈ មានតើ ទៅលេងគាត់ខែបុណ្យខែទានទិញនេះទិញនោះ (ទិញនេះទិញនោះ មានន័យថា ទិញអីវ៉ាន់) ទៅជូនគាត់។

កៈ ហើយអញ្ចឹង តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់អ្នកមីងទេ?

ខៈ ជីដូនជីតាខាងឪពុករបស់ខ្ញុំគាត់ឈ្មោះ តាម៉ៅ យាយខន។

កៈ ឈ្មោះតាម៉ៅ យាយខន! ហើយអញ្ចឹងសំរាប់ជីដូនជីតាខាងឪពុករបស់អ្នកមីងនឹង តើពួកគាត់មានស្រុកកំណើតនៅកន្លែងណាដែរ អ្នកមីង?

ខៈ ជីដូនជីតាខាងឪពុករបស់ខ្ញុំគាត់មានស្រុកកំណើតនៅភូមិផ្នត់ដំរីខាងជើង។

កៈ អូ! ពួកគាត់នៅភូមិផ្នត់ដំរីខាងជើង។ ហើយអញ្ចឹង សំរាប់ជីដូនជីតាខាងឪពុករបស់អ្នកមីង តើពួកគាត់បានកើតនៅពេលណា អ្នកមីងមាននៅចាំទេ?

ខៈ មិនចាំទេ។

កៈ ហើយអញ្ចឹង តើជីដូនជីតាខាងឪពុករបស់អ្នកមីងពួកគាត់បានស្លាប់នៅពេលណា អ្នកមីងមាននៅចាំទេ ?

ខៈ អត់ចាំទេ មិនដឹងគាត់នៅពេលណាទេ។

កៈ ហើយអញ្ចឹង ពេលដែលជីដូនជីតាខាងឪពុករបស់អ្នកមីងបានស្លាប់នឹង តើពួកគាត់មានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ ពួកគាត់អាយុច្រើនហើយ ចាស់ៗអស់ហើយនឹង។

កៈ ហើយអញ្ចឹង តើពួកគាត់បានស្លាប់នៅកន្លែងណាដែរ អ្នកមីង?

ខៈ ពួកគាត់បានស្លាប់នៅភូមិផ្អត់ដំរីខាងជើង។

កៈ ហើយអញ្ចឹង ពេលដែលអ្នកមីងបានកើតមក តើអ្នកមីងមានបានជួបជាមួយនឹងពួកគាត់ទេ?

ខៈ បានជួប។

កៈ ហើយអញ្ចឹង ពេលដែលអ្នកមីងបានជួបជាមួយនឹងពួកគាត់នឹង តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ ពេលដែលខ្ញុំជួបជាមួយនឹងពួកគាត់នឹងខ្ញុំធំដែរហើយ ខ្ញុំចេះដកចេះស្ទូងហើយ ប្រហែលដប់បួន ដប់ប្រាំឆ្នាំហើយ។

កៈ អូ! អ្នកមីងប្រហែលអាយុដប់បួន ដប់ប្រាំឆ្នាំ! ហើយអញ្ចឹង អ្នកមីងមានធ្លាប់ទៅហើយជួបជាមួយគាត់ ហើយដូចជាលេងជាមួយគាត់?

ខៈ ទៅតើ ពេលយើងទៅធ្វើការទៅចូលទៅហូបបាយជាមួយនឹងគាត់នឹង។

កៈ អូ! ពួកគាត់ធ្វើបាយអោយយើងហូប។ ហើយអញ្ចឹងសំរាប់ក្រុមគ្រួសាររបស់អ្នកមីងបានរស់នៅ ខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ ខ្ញុំរស់នៅនឹងតាំងពីកើតមកម្លេះ។

កៈ អូ! អ្នកមីងបានកើតមករស់នៅនឹងរហូតតែម្តង។ ហើយអញ្ចឹង សំរាប់អ្នកមីងមានសាច់ញាតិដទៃដែលរស់នៅក្រៅប្រទេសខ្មែរទេ អ្នកមីង?

ខៈ គ្មានទេ។

កៈ អត់មានទេ! ហើយអញ្ចឹង សំរាប់ស្វាមីរបស់អ្នកមីង តើគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ស្វាមីរបស់ខ្ញុំគាត់ឈ្មោះ សឿន រឹម។

កៈ ឈ្មោះ សឿន រឹម! ហើយអញ្ចឹង
តើអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគាត់នៅពេលណាដែរ អ្នកមីង?

ខៈ មិនដឹងឆ្នាំណាទេ ភ្លេចអស់ហើយ។

កៈ ហើយអញ្ចឹង មកដល់សព្វថ្ងៃនេះ
តើអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់បានប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ ខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយគាត់តាំងពីខ្ញុំអាយុដប់ប្រាំបួនឆ្នាំ។

កៈ
អញ្ចឹងមានន័យថាពេលដែលអ្នកមីងរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នឹងអ្នកមីងមានអាយុដប់ប្រាំបួនឆ្នាំ។ ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍នឹង រៀបចំឡើងដោយឪពុកម្តាយ ឬមួយរៀបចំឡើងដោយនរណាគេដែរ អ្នកមីង?

ខៈ ឪពុកម្តាយគាត់ជាអ្នករៀបចំអោយ។

កៈ អូ! ឪពុកម្តាយគាត់ជាអ្នករៀបចំអោយ!
ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍នឹងមានដូចជាថ្លៃ    ជំនួនទេ អ្នកមីង?

ខៈ គ្មានទេជំនាន់នឹង យកគ្នាតែម្តងនឹង។

កៈ ហើយអញ្ចឹង
តើអ្នកមីងហើយនឹងស្វាមីរបស់អ្នកមីងបានជួបគ្នាលើកដំបូងនៅពេលណាដែរ អ្នកមីង?

ខៈ ទេ មិនដឹងទេ។

កៈ អ្នកមីងអត់បានជួបគ្នាពីមុនទេ រហូតដល់ថ្ងៃរៀបការទើបបានជួបគ្នា មែនទេ អ្នកមីង?

ខៈ ចាំ!

កៈ អូ! អញ្ចឹងមានន័យថា ឪពុកម្តាយគាត់ជាអ្នកណែនាំមក។
ហើយអញ្ចឹងសំរាប់អ្នកមីងហើយប្តីរបស់អ្នកមីងរៀបអាពាហ៍ពិពាហ៍នឹង
តើមានកូនចំនួនប៉ុន្មាននាក់ដែរ អ្នកមីង?

ខៈ ខ្ញុំមានកូនចំនួនពីរនាក់។

កៈ ហើយអញ្ចឹង តើកូនរបស់អ្នកមីងមានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់ដែរ អ្នកមីង?

ខៈ មានស្រីម្នាក់ ហើយប្រុសម្នាក់។

កៈ ហើយអញ្ចឹង តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះកូនទាំងពីរនាក់បានទេ អ្នកមីង?

ខៈ កូនប្រុសឈ្មោះ សុខហៀង ហើយកូនស្រីឈ្មោះ ស៊ីណា។

កៈ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ តើកូនរបស់អ្នកមីងពួកគាត់មានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ កូនប្រុសអាយុសាមសិបប្រាំបីឆ្នាំ ហើយកូនស្រីអាយុជាម្ភៃហើយឆ្នាំមមែ។

កៈ ហើយអញ្ចឹង តើកូនប្រុសរបស់អ្នកមីងគាត់កើតឆ្នាំខ្មែរឆ្នាំអ្វីដែ អ្នកមីង?

ខៈ កូនប្រុសរបស់ខ្ញុំគាត់កើតឆ្នាំថោះ។

កៈ អូ! គាត់កើតឆ្នាំថោះអាយុសាមសិបប្រាំបីឆ្នាំ។
ហើយអញ្ចឹងសំរាប់កូនទាំងពីររបស់អ្នកមីង តើសព្វថ្ងៃនេះពួកគាត់ធ្វើការងារអ្វីដែរ អ្នកមីង?

ខៈ ពួកគេទៅស៊ីឈ្នួលគេនៅប្រទេសថៃ។

កៈ ហើយអញ្ចឹង តើពួកគាត់ទៅស៊ីឈ្នួលគេនៅប្រទេសថៃទាំងពីរនាក់តែម្តង អ្នកមីង?

ខៈ ចាំ! ទៅទាំងអស់នឹងណា។

កៈ ហើយអញ្ចឹង កូនរបស់អ្នកមីងទាំងពីរនាក់នឹងមានគ្រួសារអស់ហើយ ឬក៏នៅទេ អ្នកមីង?

ខៈ មានគ្រួសារអស់ហើយ។

កៈ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ តើអ្នកមីងមានចៅចំនួនប៉ុន្មាននាក់ហើយ អ្នកមីង?

ខៈ សព្វថ្ងៃនេះខ្ញុំមានចៅចំនួនពីរនាក់ហើយ។

កៈ ហើយអញ្ចឹង ចៅរបស់អ្នកមីងនឹង តើពួកគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ចៅស្រីឈ្មោះនិមល ហើយចៅប្រុសឈ្មោះសីហា។

កៈ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងមានចេះអាន និងសរសេរអក្សរខ្មែរទេ អ្នកមីង?

ខ៖ អូ! គ្មានចេះអីទេ សូន្យតែម្តង។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទេ អ្នកមីង?

ខ៖ គ្មានចេះអីទេ។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានបានចូលរៀននៅក្នុងសាលានឹងគេទេ អ្នកមីង?

ខ៖ រៀនជំនាន់ពលពតនៅការដ្ឋាន អត់ចេះអីទេ រៀនផងគេអោយធ្វើការផង។

ក៖ រៀនផង ធ្វើការផង! ហើយអញ្ចឹង
តើអ្នកមីងមានមិត្តភក្តិជិតស្និតដែលធំធាត់មកជាមួយគ្នាតាំងពីក្មេងមកទេ អ្នកមីង?

ខ៖ គ្មានទេ គ្មានអីមួយទេ។

ក៖ អ្នកមីងគ្មានមិត្តភក្តិសោះ! ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ
តើអ្នកមីងមានធ្វើស្រែចំការទេ អ្នកមីង?

ខ៖ សព្វថ្ងៃនេះស្រែធ្វើ ប៉ុន្តែអត់មានចំការនឹងគេទេ។

ក៖ ហើយអញ្ចឹង តើអ្នកមីងធ្វើស្រែដីទំហំប៉ុនណាដែរ អ្នកមីង?

ខ៖ ធ្វើស្រែដីទំហំមួយហិចតា។

ក៖ អូ! អញ្ចឹងដីធំតើអ្នកមីង!

ខ៖ ទាំងដីកូនទាំងដីខ្លួនឯង។

ក៖ ហើយអញ្ចឹង ក្នុងមួយឆ្នាំៗ តើបានផលស្រូវបានប្រហែលប៉ុន្មានដែរ អ្នកមីង?

ខ៖ អូ! គ្មានបានទេ គ្មានលុយទិញជី។

ក៖ ហើយអញ្ចឹង ក្រៅពីធ្វើស្រែ តើអ្នកមីងមានធ្វើការអីផ្សេងដើម្បីចិញ្ចឹមជីវិតទេ អ្នកមីង?

ខ៖ ដើរលក់ខ្មៅ ហើយនឹងជិះកង់លក់ ហើយឥលូវបានចៅមកនៅមើលចៅនឹងទៅ។

ក៖ អូ! អញ្ចឹងនៅមើលចៅមិនសូវបានលក់ទេ។ ហើយអញ្ចឹង
តាំងពីក្មេងរហូតមកដល់ពេលនេះ តើអ្នកមីងគិតថាជីវិតរបស់អ្នកមីងមានការផ្លាស់ប្តូរទេ អ្នកមីង?

ខ៖ ជីវិតរបស់ខ្ញុំពិបាក ឈឺទេនឹងទើបមកពីពេទ្យ។

ក៖ ហើយអញ្ចឹង តើមានម្ហូបណាដែលអ្នកមីងចូលចិត្តហូបជាងគេទេ អ្នកមីង?

ខ៖ គ្មានម្ហូបអីណាទេ ទិញគេមួយខាំៗហូបទៅ។

ក៖ តែអត់មានម្ហូបណាដែលអ្នកមីងចូលចិត្តហូបជាងគេតែម្តងទេ?

ខ៖ មិនដឹងចង់ណាជាងគេទេ ស្អីក៏ហូបបានដែរ ចង់ហូបអីស្លរទៅ ជូនកាលត្រីឆ្អើរទៅ ត្រសក់ត្រាំទៅ។

ក៖ ហើយអញ្ចឹងសំរាប់ល្បែងប្រជាប្រិយខ្មែរដូចជា បោះឈូង បោះអង្គញ់ ទាញព្រ័ត្រអី តើអ្នកមីងមានចូលចិត្តលេងល្បែងអ្វីទេ តាំងពីក្មេងមក?

ខ៖ កាលពីក្មេងលេងនឹងគេដែលតើ បោះអង្គញ់បោះអីនឹង ពេលចូលឆ្នាំ។

ក៖ អូ! អញ្ចឹងកាលពីក្មេងអ្នកមីងធ្លាប់លេងដែរ។ ហើយអញ្ចឹងសំរាប់បទចម្រៀងវិញ តើអ្នកមីងមានចូលចិត្តស្តាប់បទចម្រៀងណាដែលស្តាប់ហើយរៀនច្រៀងតាមតាំងពីក្មេងមកទេ អ្នកមីង?

ខ៖ អូ! មិនចេះទេ តារាំនឹងមិនចេះនឹងគេផង។

ក៖ ហើយអញ្ចឹង តើអ្នកមីងចូលចិត្តស្តាប់បទចម្រៀងទេ អ្នកមីង?

ខ៖ បើគេចាក់ទៅដឹងបទនេះទៅពិរោះដែលទៅ ហើយបើអោយចាំគ្មានចាំទេ។

ក៖ ហើយអញ្ចឹង តើមានបទចម្រៀងដែលអ្នកមីងចូលចិត្តស្តាប់ទេ អ្នកណាច្រៀងដែលអ្នកមីងចូលចិត្តស្តាប់?

ខ៖ អូ! មិនស្គាល់ទេ។

ក៖ តែអ្នកមីងចូលចិត្តស្តាប់!

ខ៖ ចាំ!

ក៖ ហើយអញ្ចឹង តើនៅក្នុងក្រុមគ្រួសាររបស់អ្នកមីង មាននរណាម្នាក់ដែលគាត់ចេះលេងឧបករណ៍ភ្លេងដែរ ឬទេ អ្នកមីង?

ខ៖ អត់មានផង។

ក៖ ហើយអញ្ចឹង
សំរាប់ផ្ទះរបស់អ្នកមីងកាលពេលដែលអ្នកមីងនៅក្មេងមានលក្ខណៈដូចម្ដេចដែរ អ្នកមីង?

ខ៖ ផ្ទះតូច។

ក៖ ហើយអញ្ចឹង ជាផ្ទះទាបជាប់នឹងដី ឬមួយផ្ទះខ្ពស់ដែរ អ្នកមីង?

ខ៖ ផ្ទះកាំជណ្ដើរបីកាំ។

ក៖ ហើយអញ្ចឹង ផ្ទះនឹងនរណាគេអ្នកធ្វើដែរ អ្នកមីង?

ខ៖ ផ្ទះនឹងឪពុកម្ដាយរបស់ខ្ញុំគាត់ជាអ្នកធ្វើ។

ក៖ ឪពុកម្ដាយរបស់អ្នកមីងគាត់ជាអ្នកធ្វើ។ ហើយអញ្ចឹងសំរាប់ផ្ទះនឹង
តើឪពុកម្ដាយរបស់អ្នកមីងគាត់បានសំភារៈមកពីណាដើម្បីធ្វើដែរ អ្នកមីង?

ខ៖ គាត់ទៅស្រុកលើទៅ ហើយគាត់ដឹកយកមកធ្វើទៅ។

ក៖ ហើយអញ្ចឹង សំភារៈទាំងអស់នឹងគាត់ទៅទិញគេ ឬមួយគាត់ទៅកាប់ដោយខ្លួនឯង?

ខ៖ គាត់ទៅកាប់ខ្លួនឯង ហើយដឹងរទេះគោយកមក។

ក៖ អូ! គាត់ទៅកាប់ខ្លួនឯងហើយដឹងតាមរទេះគោយកមក។
ហើយអញ្ចឹងសំរាប់ផ្ទះនឹងធ្វើឡើងដោយសំភារៈអ្វីខ្លះដែរ អ្នកមីង?

ខ៖ បង្កង់ឫស្សី ប្រក់ស្បូវ ហើយជញ្ជាំងស្លឹកដូង។

ក៖ ហើយអញ្ចឹងសំរាប់ផ្ទះមួយនឹង
តើនរណាគេជាអ្នកបង្រៀនអោយឪពុកម្ដាយរបស់អ្នកមីងធ្វើដែរ អ្នកមីង?

ខ៖ រកជាងគេមកជួយធ្វើ។

ក៖ អូ! ជួលជាងគេអោយធ្វើអោយ។

ខ៖ អត់ជួលគេទេ រកគេអោយមកជួយ។

ក៖ អូ! យើងជួយគ្នាទៅវិញទៅមក ពេលយើងធ្វើផ្ទះចឹង យើងហៅគេមកជួយ
ហើយពេលគេធ្វើផ្ទះវិញគេហៅយើងទៅជួយវិញ។ ហើយអញ្ចឹងសំរាប់អ្នកមីង
តើអ្នកមីងមានជំនាញដែលបន្តវេនពីក្រុមគ្រួសារដូចជា វេញវល្លិ៍ផ្ដៅ ឬក៏ជំនាញធ្វើស្ករត្នោត
ឬមួយត្បាញក្រមាត្បាញអីទេ អ្នកមីង?

ខ៖ អត់មានទេ មិនចេះសោះតែម្តង។

ក៖ ហើយអញ្ចឹង កាលសម័យពលពតគេបានយកអ្នកមីងទៅដល់ណាដែរ ហើយគេអោយអ្នកមីងធ្វើអ្វីខ្លះដែរ អ្នកមីង?

ខ៖ ទៅដល់នឹងគេចាត់តាំងអោយទៅជញ្ជូនកណ្តាប់។

ក៖ នៅឯណាដែរ អ្នកមីង?

ខ៖ នៅតាំងក្រសាំង។

ក៖ ហើយអញ្ចឹង តាំងក្រសាំងនឹង នៅកន្លែងណាដែរ អ្នកមីង?

ខ៖ នៅខេត្តកំពង់ធំ។

ក៖ អូ! អញ្ចឹងកាលជំនាន់សង្គ្រាមនឹងអ្នកមីងនៅកំពង់ធំ អត់មាននៅស្រុកយើងនេះទេ?

ខ៖ អត់មាននៅនឹងទេ គេជំលៀសយកទៅនឹង។

ក៖ ហើយអញ្ចឹង កាលនោះគេអោយអ្នកមីងធ្វើអ្វីខ្លះដែរ អ្នកមីង?

ខ៖ ទៅនឹងគេអោយជញ្ជូនកណ្តាប់នឹងណា។

ក៖ ហើយអញ្ចឹង នៅពេលសម័យពលពតនឹង តើអ្នកមីងអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ ខ្ញុំអាយុដប់ពីរឆ្នាំ។

ក៖ អាយុដប់ពីរឆ្នាំ នៅក្មេងដែរ! ហើយអញ្ចឹង នៅយើងនៅក្មេងៗចឹង ពេលនៅក្នុងជំនាន់ពលពតនឹង គេអត់សូវមានធ្វើបាបយើង ឬយ៉ាងម៉េចដែរ គេធ្វើបាបដែរ?

ខ៖ គេមិនអោយយើងដេកទេ យប់ក៏គេមិនអោយដេកដែរ គេអោយធ្វើការ ហើយខ្ញុំវាតូចជាងគេ គេអោយទៅដេក ហើយដល់ពួកពលពតមកដល់ថាបាត់មនុស្សគេទៅដាស់មកវិញ។

ក៖ វេទនាណាស់អ្នកមីង! ហើយអញ្ចឹងសំរាប់ជីវិតរបស់អ្នកមីងមានពេលដែលពិបាកជាងគេទេ អ្នកមីង?

ខ៖ ពេលគេកៀរទៅយើងនៅតូច ហើយមកទូលពោតយកមកអោយប្អូនស៊ី។

ក៖ ហើយអញ្ចឹង ពេលក្នុងសម័យពលពតនៅជុំជាមួយបងប្អូនរបស់អ្នកមីងដែរ ឬយ៉ាងម៉េចដែរ?

ខ៖ នៅជុំជាមួយបងប្អូនទាំងអស់។

ក៖ អូ! គេអោយនៅជុំគ្នាទាំងអស់ គេអត់មានអោយបែកគ្នាទេ អ្នកមីង?

ខ៖ ពេលទៅដល់នឹងឪពុកបែកផ្សេង ហើយខ្ញុំផ្សេង ហើយម្ដាយនៅជាមួយប្អូនពីរនាក់។

ក៖ ម្ដាយរបស់អ្នកមីងនៅជាមួយប្អូនពីរនាក់ ហើយអ្នកមីងនៅផ្សេង ហើយឪពុកនៅផ្សេង ហើយដល់ពេលយើងផុតសម័យនឹងមកបានយើងមកនៅជុំគ្នាវិញ ហើយវិលមកនៅស្រុកយើងវិញទៅ។

ខ៖ ចាំ!

ក៖ ហើយអញ្ចឹង តើអ្នកមីងធ្លាប់មានបទពិសោធន៍ល្អៗនៅក្នុងជីវិតដូចជា រៀបអាពាហ៍ពិពាហ៍កូនចៅ ឬក៏បុណ្យទានអីនៅនឹងផ្ទះទេ អ្នកមីង?

ខ៖ រៀបការកូនមាន។

ក៖ ហើយអញ្ចឹង តើអ្នកមីងបានរៀបការអោយកូនបានប៉ុន្មានហើយ អ្នកមីង?

ខ៖ រៀបការកូនទាំងពីរនឹងណា។

ក៖ ហើយអញ្ចឹង រៀបការកូននឹងនៅភូមិយើងនឹង ឬមួយនៅកន្លែងណាដែរ អ្នកមីង?

ខ៖ រៀបការនៅនឹង នៅភូមិយើងនឹង។

ក៖ ហើយអញ្ចឹង ពេលដែលមានកម្មវិធីដូចជារៀបការកូនចឹង តើអ្នកមីងមានអារម្មណ៍ដូចម្ដេចដែរ អ្នកមីង?

ខ៖ ខ្ញុំមានអារម្មណ៍សប្បាយ ជំពាក់គេ រកដោះគេនៅពេលក្រោយទៅ។

ក៖ អោយយើងបានរៀបការអោយកូនចៅយើងសិន។ ហើយអញ្ចឹងសំរាប់អ្នកមីងពេលនៅក្មេង តើអ្នកមីងធ្លាប់មានក្ដីសង្ឃឹមថា ពេលអ្នកមីងធំឡើងចង់ធ្វើអ្វីមួយទេ អ្នកមីង?

ខ៖ គ្មានទេ។

ក៖ គ្មានទេ អត់ដែលមានក្ដីសង្ឃឹមចង់ធ្វើអ្វីមួយទេ។

ខ៖ បើធ្វើទល់តែយើងរៀនចេះ បើយើងរៀនមិនចេះផង។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីង បើសិនជាអ្នកមីងចង់ផ្តាំផ្ញើរទៅកាន់កូនចៅជំនាន់ក្រោយ តើអ្នកមីងនឹងផ្តាំផ្ញើរអ្វីខ្លះទៅកាន់ពួកគាត់?

ខ៖ ផ្តាំផ្ញើរអោយកូនរកបាន អោយរៀនអោយចេះ កុំអោយហាត់ដូចខ្ញុំ។

ក៖ ហើយអញ្ចឹង បើអ្នកមីងចង់អោយកូនចៅរបស់អ្នកមីងជៀសវាង តើអ្នកមីងចង់អោយពួកគាត់ជៀសវាងពីអ្វីខ្លះដែរ អ្នកមីង?

ខ៖ ជៀសវាងថ្នាំញៀនកុំអោយជក់។

ក៖ សំរាប់ខ្ញុំចុងក្រោយ
អរគុណច្រើនអ្នកមីងសំរាប់ពេលវេលាដែលបានសម្ភាសន៍អ្នកមីងអំពីជីវប្រវត្តិរបស់អ្នកមីង ហើយសំរាប់ចុងក្រោយសូមជូនពរអ្នកមីងមានសុខភាពល្អ មានកំលាំងមាំមួន មានប្រាជ្ញាវៀងវៃ ហើយសូមជូនពរអោយកូនចៅអ្នកមីងគាត់មានសុខភាពល្អ មានប្រាជ្ញាវៀងវៃ កំលាំងមាំមួន ហើយអោយគាត់ជោគជ័យលើមុខរបរការងារគាត់ប្រចាំថ្ងៃ ដើម្បីគាត់អាចបន្តរីក ចំរើន ហើយដើម្បីគាត់អាចជួយអ្នកមីងផងដែរ។ អញ្ចឹង អរគុណច្រើនហើយមីង។